# នៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង
# នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

## ព័ត៌មានពិស្តារនៃការដាក់ឯកសារ

| | | |
|---|---|---|
| សំណុំរឿងលេខ | : | ០០២/១៩-០៩-២០០៧-អវតក/អជសដ |
| ដាក់ទៅ | : | អង្គជំនុំជម្រះសាលាដំបូង |
| ថ្ងៃដាក់ | : | ថ្ងៃទី១៨ ខែកក្កដា ឆ្នាំ២០១៣ |
| ភាគីអ្នកដាក់ | : | សហព្រះរាជអាជ្ញា |
| ភាសាដើម | : | អង់គ្លេស |

ឯកសារបកប្រែ
TRANSLATION/TRADUCTION
ថ្ងៃ ខែ ឆ្នាំ (Date): 18-Jul-2013, 13:24
CMS/CFO: Sann Rada

## ចំណាត់ថ្នាក់ឯកសារ

ប្រភេទឯកសារដែលស្នើឡើងដោយភាគីដាក់ឯកសារ: សាធារណៈ

ចំណាត់ថ្នាក់ឯកសារកំណត់ដោយអង្គជំនុំជម្រះ: សាធារណៈ/Public

ប្រភេទនៃចំណាត់ថ្នាក់ឯកសារ:

ការពិនិត្យចំណាត់ថ្នាក់ឯកសារបណ្ដោះអាសន្នឡើងវិញ:

ឈ្មោះមន្ត្រីដែលបានពិនិត្យ:

ហត្ថលេខា:

---

# សំណើរបស់សហព្រះរាជអាជ្ញា សុំការពិចារណាឡើងវិញលើសេចក្ដីសម្រេចទាក់ទងនឹងការបដិសេធលើសំណើសុំឲ្យកោះហៅដើមបណ្ដឹងរដ្ឋប្បវេណី ស សារិន សាជាថ្មី

---

**អ្នកដាក់ឯកសារ:**

**សហព្រះរាជអាជ្ញា:**
លោកស្រី ជា លាង
លោក Andrew CAYLEY

**អ្នកទទួលឯកសារ:**

**អង្គជំនុំជម្រះសាលាដំបូង:**
ចៅក្រម និល ណុន, ប្រធាន
ចៅក្រម Silvia CARTWRIGHT
ចៅក្រម យ៉ា សុខន
ចៅក្រម Jean-Marc LAVERGNE
ចៅក្រម យូរ ឧត្តារា

**សហមេធាវីនាំមុខតំណាងដើមបណ្ដឹងរដ្ឋប្បវេណី:**
ពេជ អង្គ
Elisabeth SIMONNEAU

**ចម្លងជូន:**

**ជនជាប់ចោទ:**
នួន ជា
ខៀវ សំផន

**មេធាវីការពារក្ដីជនជាប់ចោទ:**
លោក សុន អរុណ
លោក Victor Koppe
លោក គង់ សំអុន
លោក Jacques VERGÈS
លោក Arthur VERCKEN
លោកស្រីAnta GUISSÉ

## I. សេចក្តីផ្តើម និងប្រវត្តិនីតិវិធី

១- សហព្រះរាជអាជ្ញាស្នើអង្គជំនុំជម្រះសាលាដំបូងពិចារណាឡើងវិញ "សេចក្តីសម្រេចរបស់ខ្លួនលើសំណើសុំទាំងអស់នៃវិធានការការពារក្នុងសំណុំរឿង០០២/០១ និងចម្លើយតបទៅនឹងសំណើរបស់សហព្រះរាជអាជ្ញាសុំឲ្យកោះហៅដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ ស សារិន សាជាថ្មី និងបង្គាប់ឲ្យមានការវាយតម្លៃជាផ្លូវការមួយពីតម្រូវការចាំបាច់សម្រាប់វិធានការការពារ (ឯកសារ E286)" ដែលបានចេញនៅថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៣ ("សេចក្តីសម្រេចច្រានចោល")[1] ដែលនៅក្នុងសេចក្តីសម្រេចនេះ អង្គជំនុំជម្រះបានរកឃើញថា នឹងមិននាំទៅដល់ការស្វែងរកការពិត ឬជាផលប្រយោជន៍យុត្តិធម៌ឡើយ ដើម្បីកោះហៅដើមបណ្តឹងរដ្ឋប្បវេណី ស សារិន សាជាថ្មីនោះ (TCCP-186)។

២- នៅក្នុងបទសម្ភាសន៍ពិស្តាររបស់គាត់ជាមួយមជ្ឈមណ្ឌលឯកសារកម្ពុជា (DC Cam) នៅថ្ងៃទី៥ និងទី៦ខែឧសភា ឆ្នាំ២០០៩ ស សារិន បានបញ្ជាក់ឡើងវិញពីអង្គហេតុជាក់លាក់នានា ដែលជាប់ទាក់ទងដោយផ្ទាល់ទៅនឹងបញ្ហាទាំងឡាយនៅចំពោះមុខអង្គជំនុំជម្រះនេះនៅក្នុងសំណុំរឿង ០០២/០១ រួមទាំងព័ត៌មានទាក់ទងនឹងអំពើ និងការប្រព្រឹត្តិរបស់ជនជាប់ចោទទាំងពីរ[2]។ ក្នុងពេលផ្តល់សក្ខីកម្មរបស់ ស សារិន នៅក្នុងសំណុំរឿង ០០២/០១ កាលពីថ្ងៃទី២៩ ខែមេសា ឆ្នាំ២០១៣ គាត់បានលើកពីកង្វល់ជាលើកដំបូងចំពោះសន្តិសុខផ្ទាល់ខ្លួនរបស់គាត់ ហើយបានស្នើសុំជំនួយដើម្បីធានាចំពោះសុវត្ថិភាពរបស់គាត់[3]។ គាត់បដិសេធក្នុងការផ្តល់សក្ខីកម្មជាបន្តបើសិនជាគ្មានវិធានការការពារជាក់លាក់ដូចដែលគាត់បានស្នើសុំ[4]។ អង្គជំនុំជម្រះសាលាដំបូងបានបដិសេធសំណើសុំនេះ និងបានអនុញ្ញាតឲ្យគាត់ចេញពីសាលសវនាការ[5]។ សហព្រះរាជអាជ្ញាបានដាក់សំណើមួយ សុំឲ្យកោះហៅដើមបណ្តឹងរដ្ឋប្បវេណី ស សារិន សាជាថ្មី និងស្នើ ឲ្យមានការបង្គាប់វាយតម្លៃជាផ្លូវការមួយពីតម្រូវការចាំបាច់

---

[1] **E293** សេចក្តីសម្រេចលើសំណើសុំវិធានការការពារទាំងអស់នៅក្នុងសំណុំរឿង ០០២/០១ និង ចម្លើយតបទៅនឹងសំណើរបស់សហព្រះរាជអាជ្ញាសុំឲ្យកោះហៅដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ ស សារិន សាជាថ្មី និងបង្គាប់ឲ្យមានការវាយតម្លៃជាផ្លូវការមួយពីតម្រូវការចាំបាច់សម្រាប់វិធានការការពារ (ឯកសារ E286), ២៨ មិថុនា ២០១៣, កថាខណ្ឌទី១៣ ("សេចក្តីសម្រេចច្រានចោល")។

[2] **D230/1.1.874c** ប្រតិចារឹកនៃបទសម្ភាសន៍របស់ DC Cam ជាមួយ ស សារិន, ៥-៦ ឧសភា ២០០៩ ត្រង់ ERN 00739511, ERN 00739514, ERN 00739547-8, ERN 00739554, ERN 00739555។

[3] **E1/185.1** ប្រតិចារឹក, ២៩ មេសា ២០១៣ ត្រង់ទំព័រទី៣៧-៣៩។

[4] *ដដែលដូចខាងលើ,* ត្រង់ទំព័រទី៥០-៥២។

[5] *ដដែលដូចខាងលើ,* ត្រង់ទំព័រទី៦៤។

សម្រាប់វិធានការការពារ នៅថ្ងៃទី២០ ខែឧសភា ឆ្នាំ២០១៣ (ឯកសារ E286)[6]។ មេធាវីការពារក្ដី ខៀវ សំផន បានជំទាស់នឹងសំណើសុំឲ្យកោះហៅសាជាថ្មីនេះ (E286/1)[7]។

៣- នៅក្នុងសេចក្ដីសម្រេចច្រានចោល អង្គជំនុំជម្រះបានរកឃើញនៅក្រោយការពិគ្រោះយោបល់ជាមួយអង្គភាពគាំពារសាក្សី និងអ្នកជំនាញ (WESU) ថា ស សារិន មិនមែនជាមនុស្សដែលឲ្យគេជឿថា ការបង្ហាញខ្លួននៅចំពោះមុខអង្គជំនុំជម្រះ "ធ្វើឲ្យជីវិត ឬសុខភាពរបស់ពួកគាត់ ឬរបស់សមាជិកគ្រួសារ ឬសាច់ញាតិជិតស្និទ្ធរបស់គាត់មានគ្រោះថ្នាក់ធ្ងន់ធ្ងរឡើយ"[8]។ ហេតុដូចនេះ អង្គជំនុំជម្រះ បានចេញសេចក្ដីបង្គាប់ ដោយមានសម្អាងហេតុ និងសម្រេចថា វិធានការការពារសម្រាប់ ស សារិន មិនអនុញ្ញាតិឡើយតាមវិធាន២៩ នៃវិធានផ្ទៃក្នុង ដោយហេតុថា "ទោះបីជាមានកង្វល់ជាអត្តនោម័ត ដូចបានបញ្ជាក់ដោយដើមបណ្ដឹងរដ្ឋប្បវេណីរូបនេះក៏ដោយ ក៏ WESU មិនអាចកំណត់អត្តសញ្ញាណពីមូលដ្ឋានជាក់ស្ដែង ឬសត្យានុម័តសម្រាប់ការភ័យខ្លាចទាំងនេះ បានឡើយ"[9]។

៤- ស សារិន បានបញ្ជាក់នៅក្នុងពេលផ្ដល់ចម្លើយជូនអង្គជំនុំជម្រះសាលាដំបូង នៅថ្ងៃទី២៩ ខែមេសា ឆ្នាំ២០១៣[10] និងក្នុងពេលផ្ដល់បទសម្ភាសន៍តាមដានជាបន្ត ជូនអង្គភាព WESU ថា គាត់មិនចង់ផ្ដល់ភ័ស្ដុតាងបន្ថែមទៀតទេ បើគ្មានការផ្ដល់អន្តរាគមន៍ជាវិធានការការពារជាក់លាក់ទេនោះ គឺអង្គរ័ក្សការពារបួននាក់សម្រាប់មួយជីវិត ឬការផ្លាស់ប្ដូរទីលំនៅជាអន្តរជាតិសម្រាប់ខ្លួនគាត់ និងគ្រួសារគាត់[11]។ បន្ទាប់ពីបានទទួលរបាយការណ៍មួយពីអង្គភាព WESU អង្គជំនុំជម្រះសាលាដំបូងបានសម្រេចថា "ការកោះហៅ ស សារិន សាជាថ្មី គឺមិនទំនងថានឹងនាំទៅដល់ការស្វែងរកការពិតឬជាផលប្រយោជន៍នៃយុត្តិធម៌ទេ" ហើយ ស សារិន ក៏មិនអាច "បង្ខំឲ្យមកផ្ដល់សក្ខីកម្មបានដែរ" តាមវិធាន២៣(៤) នៃក្របខណ្ឌច្បាប់ អ.វ.ត.ក[12]។

---

[6] **E286** សំណើរបស់សហព្រះរាជអាជ្ញាសុំឲ្យកោះហៅដើមបណ្ដឹងរដ្ឋប្បវេណី ស សារិន សាជាថ្មី និងបង្គាប់ឲ្យមានការវាយតម្លៃ ជាផ្លូវការមួយពីតម្រូវការចាំបាច់សម្រាប់វិធានការការពារ, ២០ ឧសភា ២០១៣ ("សំណើរបស់សហព្រះរាជអាជ្ញា")។

[7] **E286/1** ចម្លើយតបទៅនឹងសំណើរបស់សហព្រះរាជអាជ្ញាដែលបានស្នើសុំឲ្យកោះហៅសាជាថ្មី ដើមបណ្ដឹងរដ្ឋប្បវេណី ស សារិន និងបង្គាប់ឲ្យមានការវាយតម្លៃពីតម្រូវការរបស់រូបលោកទាក់ទងនឹងវិធានការការពារខ្លួន, ៣០ ឧសភា ២០១៣។

[8] វិធាន២៩(២)។

[9] **E293** សេចក្ដីសម្រេចច្រានចោល ត្រង់កថាខណ្ឌទី១២។

[10] **E1/185.1** ប្រតិចារឹក, ២៩ មេសា ២០១៣ ត្រង់ទំព័រទី៥០-៥២។

[11] **E1/185.1** ប្រតិចារឹក, ២៩ មេសា ២០១៣ ត្រង់ទំព័រទី៣៧-៤២, ៥២ និង៥៤។ ឯកសារលេខ **E29/460** របាយការណ៍របស់ WESU, ទំព័រទី៣។

[12] **E293** សេចក្ដីសម្រេចច្រានចោល ត្រង់កថាខណ្ឌទី១៣។

៥- សហព្រះរាជអាជ្ញា សូមស្នើឲ្យមានការពិចារណាឡើងវិញលើសេចក្តីសម្រេចច្រានចោលនេះ ក្នុងស្មារតីនៃ៖

1) ការបកស្រាយខុសចំពោះវិធាន ២៣(៤) ដូចបានអនុវត្តក្នុងករណីនេះ ដែលហាមឃាត់អង្គជំនុំជម្រះសាលាដំបូងពីការបង្ខំដើមបណ្តឹងរដ្ឋប្បវេណី ស សារិន ឲ្យមកផ្តល់ភស្តុតាងនៅពេលសវនាការ ហើយនិង

2) ភាពអយុត្តិធម៌ដែលបណ្តាលមកពីការដាក់ហួតពីអង្គជំនុំជម្រះ នូវភស្តុតាងភរនីយ និងដែលពាក់ព័ន្ធ ដែលបានផ្តល់តាមរយៈសក្ខីកម្មរបស់ ស សារិន លើបញ្ហាសំខាន់ៗជាគន្លឹះនៅក្នុងករណីនេះ ឬដោយការដកហូតពីជនជាប់ចោទ នូវសិទ្ធិទទួលបាននូវការជំនុំជម្រះមួយដែលត្រឹមត្រូវនិងយុត្តិធម៌ ពីការប្រឈមមុខជាមួយនឹងភស្តុតាងប្រឆាំងនឹងខ្លួន តាមរយៈការសួរដេញដោល ស សារិន។

## II. ច្បាប់

### *ក. ការធ្វើតេស្តផ្លូវច្បាប់ សម្រាប់សំណើសុំការពិចារណាឡើងវិញ*

៦- អង្គបុរេជំនុំជម្រះធ្លាប់បានសម្រេចថា "ពាក្យសុំការពិចារណាឡើងវិញអាចនឹងជោគជ័យទៅបានគឺអាស្រ័យលើមូលដ្ឋានច្បាប់ ដើម្បីឲ្យអង្គបុរេជំនុំជម្រះពិចារណាឡើងវិញចំពោះសេចក្តីសម្រេចពីមុនរបស់ខ្លួន"[13]។ លើសពីនេះ ដោយបានលើកយោងយុត្តិសាស្ត្ររបស់បណ្តាតុលាការអន្តរជាតិនានា អង្គបុរេជំនុំជម្រះបានរកឃើញថា ខ្លួនមានអំណាចជាប់មកជាមួយដើម្បីពិចារណាឡើងវិញលើសេចក្តីសម្រេចពីមុនណាមួយរបស់ខ្លួន ក្នុងកាលៈទេសៈចំនួនបី៖ ១) គឺនៅពេលដែលការផ្លាស់ប្តូរកាលៈទេសៈអនុញ្ញាត។ ២) គឺនៅពេលដែលតុលាការរកឃើញថា សេចក្តីសម្រេចពីមុនរបស់ខ្លួននោះមានកំហុសដោយភាន់ច្រឡំ ឬ ៣) គឺនៅពេលដែលសេចក្តីសម្រេចនោះបានបង្កឲ្យមានភាពអយុត្តិធម៌[14]។

---

[13] **C22/I/41** សេចក្តីសម្រេចទទួលយកសេចក្តីសង្កេតជាទូទៅរបស់ដើមបណ្តឹងរដ្ឋប្បវេណី, ២៤ មិថុនា ២០០៨ (អង្គបុរេជំនុំជម្រះ) ត្រង់កថាខណ្ឌទី៣, ២៥។ **C22/I/68** សេចក្តីសម្រេចលើពាក្យសុំពិចារណាសាជាថ្មីអំពីសិទ្ធិរបស់ដើមបណ្តឹងរដ្ឋប្បវេណី ក្នុងការថ្លែងប្រាស្រ័យជូនអង្គបុរេជំនុំជម្រះដោយខ្លួនឯង, ២៨ សីហា ២០០៨ ត្រង់កថាខណ្ឌទី២៥។ **D99/3/41** សេចក្តីសម្រេចលើពាក្យសុំការពិចារណាឡើងវិញរបស់ អៀង សារី ចំពោះសេចក្តីសម្រេចស្តីពីការដាក់ពាក្យសុំនៅក្នុងសំណុំរឿង "ឌុច", ៣ ធ្នូ ២០០៨ ត្រង់កថាខណ្ឌទី៦។

[14] *ដដែលដូចខាងលើ។* សម្រាប់យុត្តិសាស្ត្រអន្តរជាតិ *សូមមើល រដ្ឋអាជ្ញា ទល់នឹង Stanislav Galić,* សំណុំរឿងលេខ: IT-98-29-A, ។ សាលដីកាលើពាក្យសុំការអនុញ្ញាតប្តឹងឧទ្ធរណ៍របស់អយ្យការ (អង្គជំនុំជម្រះសាលាឧទ្ធរណ៍នៃតុលាការ ICTY), ១៤ ធ្នូ ២០០១ ត្រង់

### ខ. ការបង្ហាញខ្លួនរបស់ដើមបណ្ដឹងរដ្ឋប្បវេណីនៅពេលសវនាការ

៧- យោងតាមវិធានផ្ទៃក្នុងសម្រាប់ អ.វ.ត.ក[15] មិនបានចែងឲ្យបានច្បាស់លាស់ថាតើ អង្គជំនុំជម្រះអាចបង្ខំឲ្យដើមបណ្ដឹងរដ្ឋប្បវេណីផ្ដល់ភ័ស្ដុតាងនៅក្នុងសវនាការបានឬអត់។ ការវិភាគខាងក្រោមនឹងបង្ហាញឲ្យឃើញថា អង្គជំនុំជម្រះសាលាដំបូងពិតជាមានអំណាចនេះ។ អង្គជំនុំជម្រះសាលាដំបូងអាចកោះហៅដើមបណ្ដឹងរដ្ឋប្បវេណីណាម្នាក់ ឲ្យចូលមកបង្ហាញខ្លួននៅចំពោះមុខ អ.វ.ត.ក ទោះជាតាមគំនិតផ្ដួចផ្ដើមរបស់ខ្លួនឬតាមសំណើរបស់ភាគីណាមួយ[16]ឲ្យតែការកោះហៅនោះ“មានចុះនិទ្ទេសរបស់បុគ្គលដែលត្រូវកោះហៅនោះ”[17]។ ប្រាកដណាស់ថាជនរងគ្រោះជាដើមបណ្ដឹងរដ្ឋប្បវេណីម្នាក់អាចត្រូវបានកោះហៅដោយមានចុះនិទ្ទេសរបស់ដើមបណ្ដឹងរដ្ឋប្បវេណី[18]។ ដើមបណ្ដឹងរដ្ឋប្បវេណីមានសិទ្ធិមកបង្ហាញខ្លួនក្នុងពេលសវនាការ តាមរយៈសហមេធាវីនាំមុខដើមបណ្ដឹងរដ្ឋប្បវេណី[19] ហេតុដូច្នេះ វិធានផ្ទៃក្នុងមិនដាក់លក្ខខណ្ឌតម្រូវឲ្យដើមបណ្ដឹងរដ្ឋប្បវេណីត្រូវតែបង្ហាញខ្លួននៅពេលសវនាការទេ[20]។

### គ. សក្ខីកម្មរបស់ដើមបណ្ដឹងរដ្ឋប្បវេណីនៅពេលសវនាការ

៨- វិធានបានចែងថា ដើមបណ្ដឹងរដ្ឋប្បវេណីមានសិទ្ធិផ្ដល់សក្ខីកម្មនៅពេលសវនាការ[21]។ ស្រដៀងគ្នានេះដែរ តាមក្រមនីតិវិធីរបស់កម្ពុជា និងបារាំង[22] ដើមបណ្ដឹងរដ្ឋប្បវេណី មានសិទ្ធិ ធ្វើសេចក្ដីថ្លែង

កថាខណ្ឌទី១៣។ *រដ្ឋអាជ្ញា ទល់នឹង Fulgence Kayishema,* សំណុំរឿងលេខ: ICTR-01-67-R11*ស្ទួន,* សេចក្ដីសម្រេចលើសំណើសុំការពិចារណាឡើងវិញរបស់រដ្ឋអាជ្ញា ឬតាមជម្រើសផ្សេង សុំការបញ្ជាក់លើបណ្ដឹងឧទ្ធរណ៍បន្ទាន់បង្ខំ (អង្គជំនុំជម្រះសាលាដំបូងនៃតុលាការ ICTR), ៣ កុម្ភៈ ២០១១ ត្រង់កថាខណ្ឌទី៣។ *រដ្ឋអាជ្ញា ទល់នឹង Stanislav Galić,* IT-98-29-A, សាលដីកាលើសំណើសុំការពិចារណាឡើងវិញរបស់មេធាវីការពារក្ដី (អង្គជំនុំជម្រះសាលាឧទ្ធរណ៍នៃតុលាការ ICTY), ១៦ កក្កដា ២០០៤ ត្រង់កថាខណ្ឌទី២។

[15] អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា, វិធានផ្ទៃក្នុង(វិសោធនកម្មលើកទី៨) វិសោធនកម្មនៅថ្ងៃទី០៣ ខែសីហា ឆ្នាំ២០១១ (“វិធានផ្ទៃក្នុង”)។

[16] សូមមើល វិធាន៤១, វិធាន៨០ស្ទួន។

[17] វិធាន៤១(១)។

[18] វិធាន៤១(១)៖ “ដីកាកោះគឺជាការបង្គាប់ដល់បុគ្គលណាម្នាក់ ឲ្យចូលមកបង្ហាញខ្លួននៅចំពោះមុខអង្គជំនុំជម្រះវិសាមញ្ញ។ ដីកាអាចអនុវត្តចំពោះ... សាក្សី ឬដើមបណ្ដឹងរដ្ឋប្បវេណី ហើយត្រូវមានចុះនិទ្ទេសរបស់បុគ្គល ដែលត្រូវកោះហៅនោះផង។ *ដដែលដូចខាងលើ*។

[19] វិធាន២៣(៣)។

[20] វិធាន៨៣ គ្រប់គ្រងលើការចូលមកបង្ហាញខ្លួនដោយដើមបណ្ដឹងរដ្ឋប្បវេណី ត្រូវបានទុកជាមោឃៈនៅថ្ងៃទី៩ ខែកុម្ភៈ ឆ្នាំ២០១០។

[21] វិធាន៩១(១)។“អង្គជំនុំជម្រះសាលាដំបូងត្រូវស្ដាប់ចម្លើយដើមបណ្ដឹងរដ្ឋប្បវេណី...ទៅតាមលំដាប់ដែលខ្លួនយល់ឃើញថាមានប្រយោជន៍”។ *ដដែលដូចគ្នានឹងខាងលើ* ។

[22] ក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា, មាត្រា៣២៦, ៣៣៥ (ឆ្នាំ២០០៨)។ Code de Procédure Pénale Art. 346 (2013)។

ក្នុងអំឡុងពេលសវនាការ។ ខណៈដែលវិធាន២៣(៤) ចែងយ៉ាងច្បាស់ថា ដើមបណ្តឹងរដ្ឋប្បវេណី "មិនត្រូវបានគេសាកសួរ ដូចសាក្សីធម្មតាក្នុងរឿងក្តីតែមួយនេះបានទេ ហើយស្របតាមវិធាន៦២ ដែលទាក់ទងនឹងដីកាចាត់ឲ្យស៊ើបសួរជំនួស អាចត្រូវបានគេស្តាប់ចម្លើយតែប៉ុណ្ណោះ ដោយស្ថិតក្រោមលក្ខខណ្ឌដូចគ្នាទៅ នឹងជនត្រូវចោទ ឬ ជនជាប់ចោទដែរ" វិធាននេះតែឯងគឺមិនគ្រប់គ្រាន់ទេ នៅក្នុងការកំណត់ថា តើដើមបណ្តឹងរដ្ឋប្បវេណីណា ដែលអាចត្រូវបង្គាប់ឲ្យផ្តល់ភ័ស្តុតាង នៅពេលសវនាការ។ ទោះបីជាយ៉ាងណាក៏ដោយ ការវិភាគទាំងស្រុងមួយលើវិធាន និង ការពិចារណាលើប្រភពពាក់ព័ន្ធនានាផ្នែកច្បាប់[23] បានបញ្ជាក់យ៉ាងច្បាស់ថា ដើមបណ្តឹងរដ្ឋប្បវេណីអាចត្រូវបង្គាប់ឲ្យផ្តល់សក្ខីកម្ម ហើយសិទ្ធិរបស់ពួកគាត់គឺខុសគ្នា ពីសិទ្ធិរបស់ជនជាប់ចោទ ទាក់ទងនឹងបញ្ហាស្តីពីការសួរដេញដោល។

៩- នៅក្នុងទិដ្ឋភាពជាច្រើនយ៉ាង សិទ្ធិរបស់ដើមបណ្តឹងរដ្ឋប្បវេណីនៅពេលសវនាការ គឺស្រដៀងគ្នាទៅនឹងសិទ្ធិរបស់ជនជាប់ចោទ។ ជនជាប់ចោទអាចត្រូវបង្គាប់ឲ្យមកបង្ហាញខ្លួនក្នុងសវនាការ[24] ហើយដើមបណ្តឹងរដ្ឋប្បវេណីដែលត្រូវបានកោះហៅយ៉ាងសមស្របហើយនោះ ក៏អាចត្រូវបង្គាប់ឲ្យមកបង្ហាញខ្លួនក្នុងសវនាការដូចគ្នាដែរ[25]។ ជនជាប់ចោទអាចផ្តល់សេចក្តីថ្លែងដែលមិនបានស្បថ[26] អាចត្រូវសួរដេញដោល[27] និងពោលអះអាងពីសិទ្ធិប្រឆាំងនឹងការដាក់ពិរុទ្ធលើខ្លួនឯង[28]។ ដូចគ្នានេះដែរ ដើមបណ្តឹងរដ្ឋប្បវេណីក៏អាចផ្តល់សេចក្តីថ្លែងដែលមិនបានស្បថ[29] អាចត្រូវសួរដេញដោល[30] និងពោលអះអាងពីសិទ្ធិប្រឆាំងនឹងការដាក់ពិរុទ្ធលើខ្លួនឯង[31]។

---

[23] មាត្រា៣១២ នៃក្រមនីតិវិធីព្រហ្មទណ្ឌបារាំងអនុញ្ញាតឲ្យ "ព្រះរាជអាជ្ញា និងមេធាវីរបស់ភាគីនានា សួរសំនួរដោយផ្ទាល់ទៅកាន់ជនជាប់ចោទ, ដើមបណ្តឹងរដ្ឋប្បវេណី, សាក្សី ឬ បុគ្គលដទៃទៀត ដែលបានកោះហៅឲ្យមកផ្តល់សក្ខីកម្ម"។ ក្រមនីតិវិធីព្រហ្មទណ្ឌ មាត្រា៣១២ (ឆ្នាំ២០១៣) (សង្កត់ន័យបន្ថែមដោយអក្សរទ្រេត)។ ភាសានេះគាំទ្រដល់ការបកស្រាយដែលថាដើមបណ្តឹងរដ្ឋប្បវេណីអាចនឹងត្រូវបានកោះហៅឲ្យមកផ្តល់សក្ខីកម្មក្នុងអំឡុងពេលសវនាការ។ ក្រមនីតិវិធីព្រហ្មទណ្ឌ មាត្រា៣៤៦ (ឆ្នាំ២០១៣) ("សាក្សីដែលបានកោះហៅដោយព្រះរាជអាជ្ញា ឬដោយភាគីនានា ត្រូវបានស្តាប់ចម្លើយក្នុងអំឡុងពេលនៃការសួរដេញដោល")។

[24] វិធាន៨១។

[25] *សូមអាន* កថាខណ្ឌ*ខាងលើទី* ១០-១២។

[26] វិធាន៩៤(ឃ)។

[27] វិធាន៩០។ *សូមអានផងដែរ* វិធាន៨៩*ស្ទួន*(២)។

[28] វិធាន២១(ឃ)។ ច្បាប់ អ.វ.ត.ក, មាត្រា៣៥ថ្មី(ឆ)។

[29] វិធាន៩១(១)។

[30] វិធាន៩១(២)។

[31] វិធាន២៨។

១០- យ៉ាងណាក៏ដោយ វាមិនដូចជាជនត្រូវចោទ ឬជនជាប់ចោទនោះទេ ដើមបណ្តឹងរដ្ឋប្បវេណី ជាទូទៅ មិនមានសិទ្ធិនៅស្ងៀមមិនឆ្លើយតបនោះទេ[32]។ សិទ្ធិនៅស្ងៀមមិនឆ្លើយតបរបស់ជនជាប់ចោទ មានឫសគល់យ៉ាងច្បាស់លាស់នៅក្នុងឯកសារអន្តរជាតិ និងច្បាប់ស្តីពីការបង្កើត អ.វ.ត.ក ហើយអាចត្រូវអនុវត្តដោយពុំមានមូលហេតុជាក់លាក់ណាមួយឡើយ[33]។ ផ្ទុយទៅវិញ ដើមបណ្តឹងរដ្ឋប្បវេណី អាចបដិសេធបានតែចំពោះការឆ្លើយតប ទៅនឹងសំណួរទាំងឡាយណាដែលចម្លើយនោះ នឹងទោរទន់ទៅរកការដាក់ពិរុទ្ធលើខ្លួនឯងប៉ុណ្ណោះ។ និយាយម្យ៉ាងទៀត ដើមបណ្តឹងរដ្ឋប្បវេណីមិនអាចបដិសេធទៅនឹងការឆ្លើយតបទៅនឹងសំណួរនានា ដោយមានមូលដ្ឋាននៅលើសំណើការពារមួយ ដែលគេមិនបានផ្តល់ឲ្យ ដែលត្រូវបានដាក់ជូនទៅអង្គជំនុំជម្រះ ធ្វើជាឱសានវាទនោះទេ។

១១- ដូចបានកត់សម្គាល់ខាងលើ វិធាន២៣(៤) ចែងថា ដើមបណ្តឹងរដ្ឋប្បវេណី “អាចត្រូវបានគេស្តាប់ចម្លើយតែប៉ុណ្ណោះ ដោយស្ថិតក្រោមលក្ខខណ្ឌដូចគ្នាទៅនឹងជនត្រូវចោទ ឬ ជនជាប់ចោទ ដែរ”[34]។ ខណៈដែលមើលមួយភ្លែតទៅ វិធានទំនងជាបញ្ជាក់ថា ដើមបណ្តឹងរដ្ឋប្បវេណី ត្រូវបានស្តាប់ចម្លើយនៅក្រោមលក្ខខណ្ឌនានា ដូចគ្នាបេះបិទទៅនឹងលក្ខខណ្ឌដែលបានអនុញ្ញាតឲ្យ ឬតម្រូវឲ្យសម្រាប់ជនជាប់ចោទនៅពេលសវនាការ នោះការវិភាគមួយលើវិធាននេះ នៅក្នុងបរិបទនៃវិធានផ្ទៃក្នុងទាំងមូល បានបញ្ជាក់យ៉ាងច្បាស់ថា ការបកស្រាយនោះគឺមានកំហុស។

១២- ***ដំណាក់កាលនៃកិច្ចស៊ើបសួរ :*** នៅក្នុងដំណាក់កាលនៃកិច្ចស៊ើបសួរ វិធាននេះអនុញ្ញាតឲ្យមានការសួរដេញដោលដើមបណ្តឹងរដ្ឋប្បវេណីនៅក្នុងស្ថានភាពខុសគ្នាពីជនត្រូវចោទ។ សហចៅក្រមស៊ើបអង្កេត

---

[32] វិធាន២១(ឃ)។ “ជនណាដែលត្រូវបានសង្ស័យ ឬ ត្រូវបានចោទប្រកាន់ ... ត្រូវផ្តល់ព័ត៌មានដល់គេ អំពីសិទ្ធិនៅស្ងៀមមិនឆ្លើយតប”។ *ដដែលដូចគ្នានឹងខាងលើ*។

[33] មាត្រា៣៥ថ្មី(ឆ) នៃច្បាប់ អ.វ.ត.ក។ វិធាន២១(ឃ)។ កតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និង នយោបាយ មាត្រា១៤(៣)(ឆ)។

[34] បន្ថែមលើនេះ លទ្ធភាពនៅក្នុងការស្តាប់ចម្លើយដើមបណ្តឹងរដ្ឋប្បវេណី គឺស្ថិតនៅក្រោមវិធាន ៦២ ទាក់ទងនឹង ដីកាចាត់ឲ្យស៊ើបសួរជំនួស។ វិធាន២៤(៤)។ វិធាន៦២ អនុញ្ញាតឲ្យសហចៅក្រមស៊ើបអង្កេតចេញដីកាចាត់ឲ្យស៊ើបសួរជំនួស ដែលតម្រូវឲ្យអ្នកស៊ើបអង្កេតណាមួយនៅក្នុងការិយាល័យរបស់ខ្លួន ឬតម្រូវឲ្យនគរបាលយុត្តិធម៌ ចេញទៅធ្វើការស៊ើបសួរ។ នៅក្នុងកាលៈទេសៈនេះ លក្ខខណ្ឌនៃការស្តាប់/សួរចម្លើយជនត្រូវចោទ និងដើមបណ្តឹងរដ្ឋប្បវេណី គឺមិនដូចគ្នាទេ។ យោងតាមវិធាន៦២(៣)(ខ) ទាំងនគរបាលយុត្តិធម៌ និងទាំងអ្នកស៊ើបអង្កេត ត្រូវបានហាមឃាត់មិនឲ្យសួរចម្លើយជនត្រូវចោទទេ។ ផ្ទុយទៅវិញ គេអនុញ្ញាតឲ្យអ្នកស៊ើបអង្កេតស្តាប់ចម្លើយដើមបណ្តឹងរដ្ឋប្បវេណី នៅក្រោមលក្ខខណ្ឌតម្រូវជាក់លាក់មួយចំនួន។ វិធាន៦២(៣)(ខ)។ លក្ខខណ្ឌទាំងនេះ រួមមាន ការព្រមឲ្យស្តាប់ចម្លើយពីសំណាក់ដើមបណ្តឹងរដ្ឋប្បវេណី ការលះបង់សិទ្ធិរបស់ដើមបណ្តឹងរដ្ឋប្បវេណីស្តីពីការមានវត្តមានរបស់មេធាវីការពារក្តី និង អវត្តមានរបស់ភាគីដទៃទៀតក្នុងអំឡុងពេលនៃការស្តាប់ចម្លើយ។ វិធាន៥៩(៦)។

អាច "ចាត់វិធានការស៊ើបសួរ ដែលនាំទៅរកការបង្ហាញការពិត" រួមទាំង ការកោះហៅ និងការសួរដេញដោលជនត្រូវចោទ ជនរងគ្រោះ និង សាក្សី ផង[35]។ វិធាន៥៨ គ្រប់គ្រងលើការសួរចម្លើយជនត្រូវចោទ និងវិធាន៥៩ គ្រប់គ្រងលើការស្តាប់ចម្លើយដើមបណ្តឹងរដ្ឋប្បវេណី។ វិធានបានចែងពីលក្ខខណ្ឌតម្រូវជាចាំបាច់ជាការសំខាន់ផ្សេងៗពីគ្នា សម្រាប់ការសួរនិងការស្តាប់ចម្លើយទាំងនេះ[36]។ ជាឧទាហរណ៍ វិធាន៥៩ អនុញ្ញាតឲ្យគេស្តាប់ចម្លើយ ដើមបណ្តឹងរដ្ឋប្បវេណី ដោយពុំមានវត្តមានមេធាវីរបស់គាត់ បើមេធាវីរូបនោះ ខកខានមិនបានបង្ហាញខ្លួន ក្រោយពីត្រូវបានកោះហៅយ៉ាងសុពលរួចហើយ[37]។ ផ្ទុយទៅវិញ វិធាន៥៨ ចែងថា ជនត្រូវចោទ អាចត្រូវបានសួរដេញដោលតែនៅចំពោះវត្តមានរបស់មេធាវី ប៉ុណ្ណោះលើកលែងតែជនត្រូវចោទរូបនោះ លះបង់សិទ្ធិក្នុងការមាន វត្តមានរបស់មេធាវី[38] ឬ នៅពេលដែលជនត្រូវចោទរូបនោះ យល់ស្របទៅនឹងស្ថានភាពប្រថុចប្រញ៉ាច[39]។

១៣- ភាពខុសពីគ្នាដ៏សំខាន់មួយទៀតទាក់ទងទៅនឹង ថាតើនរណាអាចជាអ្នកមានវត្តមានក្នុងអំឡុងពេលសួរចម្លើយនោះ។ កាលណាជនត្រូវចោទត្រូវបានសួរចម្លើយ សហចៅក្រមស៊ើបអង្កេត ត្រូវតែជូនដំណឹងដល់សហព្រះរាជអាជ្ញា ដែលបន្ទាប់មកទៀតគាត់អាចនឹងចូលរួមនៅក្នុងការសួរចម្លើយ និងអាចស្នើសុំ ថាសំនួរទាំងអម្បាលម៉ាននោះត្រូវសួរទៅកាន់ជនត្រូវចោទ[40]។ ផ្ទុយទៅវិញ លើកលែងតែសហចៅក្រម ស៊ើបអង្កេត សម្រេចតទល់ជាមួយនឹងដើមបណ្តឹងរដ្ឋប្បវេណីដោយផ្ទាល់ជាមួយនឹងភាគីឬសាក្សីដទៃទៀតណាមួយក៏ដោយ ភាគីដទៃទាំងនោះមិនត្រូវមានវត្តមាន នៅក្នុងអំឡុងពេលនៃការស្តាប់ចម្លើយ ដើមបណ្តឹងរដ្ឋប្បវេណីរូបនោះឡើយ[41]។

១៤- ***ដំណាក់កាលជំនុំជម្រះក្តី*** : នៅក្នុងដំណាក់កាលជំនុំជម្រះក្តី ខណៈដែលលក្ខខណ្ឌមួយចំនួនសម្រាប់ធ្វើការសួរចម្លើយជនជាប់ចោទ និងដើមបណ្តឹងរដ្ឋប្បវេណី គឺមានលក្ខណៈដូចគ្នា ឬស្រដៀងគ្នា (ដូចជា

---

[35] វិធាន៥៥(៥)។ សូមកត់សម្គាល់ថា ក្នុងអំឡុងពេលនៃកិច្ចស៊ើបសួរ ជនរងគ្រោះមួយចំនួនអាចស្ថិតនៅក្នុងកិច្ចដំណើរការនៃការដាក់ពាក្យសុំឲ្យគេទទួលយក និងចូលរួម ធ្វើជាដើមបណ្តឹងរដ្ឋប្បវេណី។ *សូមអាន* វិធាន ២៣ស្ទួន។

[36] *សូមអាន ឧទា.* វិធាន២៥ ដែលតម្រូវឲ្យសហព្រះរាជអាជ្ញា និងសហចៅក្រមស៊ើបអង្កេត ថតសម្លេង ឬរូបភាព នៅពេលសួរចម្លើយជនត្រូវចោទ កាលណាមានលទ្ធភាពអាចធ្វើទៅបាន។

[37] វិធាន៥៩(២)។

[38] វិធាន៥៨(២)។

[39] វិធាន៥៩(៣)។

[40] វិធាន៥៨(៤)។

[41] វិធាន៥៩(៣)។

ថា ទាំងពីរនាក់នោះ អាចត្រូវបង្គាប់ឲ្យមកបង្ហាញខ្លួនក្នុងសវនាការ[42] ឲ្យផ្តល់សេចក្តីថ្លែងដែល មិនបានស្បថ[43] ត្រូវបានតំណាងដោយក្រុមមេធាវីការពារក្តី[44] និង ពោលអះអាងពីសិទ្ធិប្រឆាំងនឹង ការដាក់ពិរុទ្ធលើខ្លួនឯង[45]) ដោយទាក់ទង ទៅនឹងទិដ្ឋភាពមួយចំនួនលក្ខខណ្ឌទាំងនោះ គឺមិនដូចគ្នា បេះបិទនោះទេ។ ខណៈដែលគេត្រូវតែប្រាប់ នូវសិទ្ធិប្រឆាំងនឹងការដាក់ពិរុទ្ធលើខ្លួនឯង ដល់ដើមបណ្តឹងរដ្ឋប្បវេណី[46] នោះគេត្រូវតែប្រាប់នូវរាល់សិទ្ធិ ទាំងអស់តាមវិធាន២១(១)(ឃ) ដល់ជនជាប់ចោទរួមទាំង សិទ្ធិនៅស្ងៀមមិនឆ្លើយតបនោះផង[47]។ ការណ៍នេះ គឺជាលក្ខណៈឆ្លុះបញ្ចាំងលើភាពខុសពីគ្នាដែល បានគូសសម្គាល់នេះស្តីពីសិទ្ធិជាមូលដ្ឋាន របស់ដើមបណ្តឹងរដ្ឋប្បវេណី និងរបស់ជនជាប់ចោទ ដូចដែលបានពិភាក្សានៅខាងលើស្រាប់៖ ដើមបណ្តឹងរដ្ឋប្បវេណី អាចបដិសេធមិនធ្វើការឆ្លើយតបតែទៅនឹងសំនួរទាំងឡាយណាដែលមានមូលដ្ឋាននៅលើការអនុវត្តដ៏សុពល នៃសិទ្ធិប្រឆាំងនឹងការដាក់ពិរុទ្ធលើខ្លួនឯងប៉ុណ្ណោះ[48]។ លើសពីនេះ នីតិវិធីជាក់លាក់មួយចំនួនដែលអនុវត្តចំពោះការសួរដេញដោលជនជាប់ចោទ គឺផ្សេងគ្នាពីនីតិវិធីសម្រាប់ដើមបណ្តឹងរដ្ឋប្បវេណី។ នៅពេលដែលចៅក្រមនានាធ្វើការសួរដេញដោល ជនជាប់ចោទ នោះត្រូវតែបានធ្វើឡើងតាមរយៈលោកប្រធាន(វិធាន៩០(២)) ការណ៍ដូចគ្នានោះមិនអនុវត្ត នៅក្នុងការសួរដេញដោល ដើមបណ្តឹងរដ្ឋប្បវេណីនោះទេ (វិធាន៩១(២))។ ជាចុងបញ្ចប់ ខណៈដែល អង្គជំនុំជម្រះអាចនឹងបង្គាប់ឲ្យគេសួរដេញដោលដល់ទីកន្លែងរបស់ជនជាប់ចោទ (នៅចំពោះវត្តមានរបស់មេធាវីការពារក្តី) នៅពេលដែលជនជាប់ចោទរូបនោះមិនមានលទ្ធភាពអាចមក បង្ហាញខ្លួននៅចំពោះមុខអង្គជំនុំជម្រះបាននោះ[49] នោះវាពុំមានបទប្បញ្ញត្តិបែបដូច្នេះទាល់តែសោះ សម្រាប់ធ្វើការសួរដេញដោលដើមបណ្តឹងរដ្ឋប្បវេណី។

---

[42] វិធាន៨១។ កថាខណ្ឌ*ខាងលើទី* ១០-១២។

[43] វិធាន៩៤(ឃ)។ វិធាន៩១(១)។

[44] វិធាន២៣ ស្ទួនពីរ។ វិធាន២១(ឃ)។

[45] មាត្រា៣៥ថ្មី(ឆ) នៃច្បាប់ អ.វ.ត.ក។ វិធាន ២៨។ កតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និង នយោបាយ មាត្រា១៤(៣)(ឆ), អនុវត្តដោយផ្ទាល់នៅ អ.វ.ត.ក ដោយអនុលោមតាមមាត្រា៣៣ថ្មី នៃច្បាប់ អ.វ.ត.ក។ អនុសញ្ញាអឺរ៉ុបស្តីពីសិទ្ធិមនុស្ស មាត្រា៦(១)។

[46] វិធាន២៨(២)។

[47] វិធាន៩០(១) ដោយបានយោងវិធាន២១(ឃ) ("ជនណាដែលត្រូវបានសង្ស័យ ឬ ត្រូវបានចោទប្រកាន់ ត្រូវចាត់ទុកថាគ្មានទោស ដរាបណាពិរុទ្ធភាពរបស់គេមិនទាន់ត្រូវបានរកឃើញ។ ជនទាំងនេះមានសិទ្ធិទទួលដំណឹងអំពីបទល្មើសដែលចោទប្រកាន់ចំពោះខ្លួន និង មានមេធាវីការពារតាមការជ្រើសរើសរបស់ខ្លួន ហើយនិង នៅក្នុងគ្រប់ដំណាក់កាលទាំងអស់នៃកិច្ចដំណើរការនីតិវិធី ត្រូវផ្តល់ព័ត៌មានដល់គេអំពីសិទ្ធិនៅស្ងៀមមិនឆ្លើយតប")។

[48] វិធាន២៨។

[49] វិធាន៨១(៦)។

១៥-ហេតុដូច្នេះ សហព្រះរាជអាជ្ញាសូមធ្វើសេចក្តីសន្និដ្ឋានថា មានការខុសគ្នាយ៉ាងខ្លាំងទាំងអំពីសិទ្ធិ របស់ជនជាប់ចោទ និងដើមបណ្តឹងរដ្ឋប្បវេណីផ្អែកតាមនីតិវិធី នឹងទាំងអំពីលក្ខខណ្ឌដែលពួកគេត្រូវបាន ចោទសួរដេញដោលនៅក្នុងដំណាក់កាលផ្សេងៗនៃដំណើរការនីតិវិធី។ ហេតុដូចនេះ សេចក្តីសន្និដ្ឋាន ដែលថា ស សារិន មិនអាចត្រូវបាន "បង្ខំឲ្យធ្វើសក្ខីកម្ម" តាមវិធាន២៣(៤)នៃវិធានផ្ទៃក្នុងនៃក្របខណ្ឌគតិយុត្តិរបស់អវតក [50] ដោយសារតែឋានៈជាដើមបណ្តឹងរដ្ឋប្បវេណីរបស់គាត់នោះ គឺជាការខុស ។ ដើមបណ្តឹងរដ្ឋប្បវេណីណាម្នាក់ ដែលភ័ស្តុតាងរបស់គាត់ត្រូវបានអង្គជំនុំជម្រះយល់ឃើញថា នាំមកនូវ ការបញ្ជាក់ការពិតអំពីការចោទប្រកាន់នានាដូចមាននៅក្នុងដីកាដំណោះស្រាយ អាចត្រូវបានបង្ខំឲ្យចូលខ្លួននៅក្នុងសវនាការ ដើម្បីធ្វើការសួរដេញដោល។

១៦-ប្រធានអង្គជំនុំជម្រះមានភារកិច្ចក្នុងការ "ដឹកនាំកិច្ចដំណើរការនីតិវិធី" ប្រយោជន៍ ដើម្បីឲ្យកិច្ចដំណើរការនីតិវិធីទាំងនោះ "នាំមកនូវការបញ្ជាក់ការពិត"[51]។ លើសពីនេះ ប្រធានអង្គជំនុំជម្រះត្រូវតែ "រក្សាសណ្តាប់ធ្នាប់ល្អនៅក្នុងអម្លុងពេលជំនុំជម្រះក្តី"[52]។ អនុលោមតាមវិធាន៣៥នៃវិធានផ្ទៃក្នុង អង្គជំនុំជម្រះសាលាដំបូង មានសិទ្ធិអំណាចក្នុងការចេញដីកាសម្រេចដាក់ទណ្ឌកម្មប្រឆាំង ចំពោះជនណាដែលជ្រៀតជ្រែកចូលនៅក្នុងកិច្ចការគ្រប់គ្រងរដ្ឋបាលរបស់តុលាការ រួមទាំង "ជនណាដែល ជ្រៀតជ្រែកចូលដោយបានដឹង ឬដោយចេតនានៅក្នុងកិច្ចការគ្រប់គ្រងរដ្ឋបាលរបស់តុលាការ" ដោយសារការខកខានក្នុងការគោរពអនុវត្តតាមដីកាបង្គាប់ឲ្យមកចូលរួម ឬ ឲ្យផ្តល់នូវឯកសារឬភ័ស្តុតាងផ្សេងៗទៀត នៅចំពោះមុខខ្លួនផងដែរ[53]។ តុលាការអន្តរជាតិនានាបានប្រើប្រាស់សិទ្ធិអំណាចរបស់ខ្លួនដើម្បីដាក់ទណ្ឌកម្មចំពោះសាក្សីដែលមិនគោរពតាមការបង្គាប់របស់តុលាការ ពីបទជ្រៀតជ្រែកចូលក្នុងកិច្ចការគ្រប់គ្រងរដ្ឋបាលរបស់តុលាការ[54]។ ជាពិសេសតុលាការនានា បានយល់ឃើញថា សាក្សីមិនគោរពតាមការបង្គាប់ ដោយសារការបដិសេធមិនព្រមមកផ្តល់សក្ខីកម្ម[55]។

---

[50] ឯកសារលេខE293 ការបដិសេធសេចក្តីសម្រេច ត្រង់កថាខណ្ឌទី១៣។

[51] វិធាន៨៥(១) នៃវធានផ្ទៃក្នុង។

[52] វិធាន៨៥(២) នៃវធានផ្ទៃក្នុង។

[53] វិធាន៣៥(១)(ខ) នៃវធានផ្ទៃក្នុង។

[54] *សូមអាន ឧទា. ករណីរឿងក្តីរបស់ រដ្ឋអាជ្ញា ទល់នឹង Nshogoza*, សំណុំរឿងលេខ ICTR-07-91-T, សាលក្រម (ថ្ងៃទី៧ កក្កដា២០០៩)។ *ករណីរឿងក្តីរបស់ រដ្ឋអាជ្ញា ទល់នឹង Marijačić និង Rebicć* សំណុំរឿងលេខ IT-95-14-A, សាលក្រម (ថ្ងៃទី២៧ កញ្ញា ២០០៦)។

[55] *សូមអាន ឧទា. ករណីរឿងក្តីរបស់ រដ្ឋអាជ្ញា ទល់នឹង Milošević*, សំណុំរឿងលេខ IT-01-54-A, *សេចក្តីសំរេចលើបណ្តឹងឧទ្ធរណ៍លើបញ្ហាបន្ទាន់បង្ខំនៅក្នុងដំណើរការនីតិវិធីស្តីពីការប្រមាថមើលងាយតុលាការរបស់ Kosta Bulatovic* (ចុះថ្ងៃទី២៩ សីហា ២០០៥)។

ដោយសារតែអង្គជំនុំជម្រះ បានយល់ឃើញថា ហានិភ័យនៃការខូចខាតដែលបានពោលអះអាងដោយ ស សារិន និងការបដិសេធជាផ្លូវការមិនផ្ដល់ជូនគាត់ នូវវិធានការការពារផ្សេងៗ សំណើរបស់គាត់ដែលសុំផ្ដល់នូវវិធានការការពារដែលមាន ភាពទូលំទូលាយមិនច្បាស់លាស់ និងគ្មានមូលដ្ឋានត្រឹមត្រូវ ដែលមិនបង្កើតបានជា "ការអនុគ្រោះលើកលែងដោយមានមូលហេតុត្រឹមត្រូវ" ណាមួយដែលនឹងអនុញ្ញាតឱ្យគាត់បដិសេធមិនចូលរួម និងមិនផ្ដល់ភ័ស្តុតាងជូនអង្គជំនុំជម្រះឡើយ[56]។ ហេតុនេះ បន្ទាប់ពីការកោះហៅសារជាថ្មី ស សារិន ត្រូវតែផ្ដល់សក្ខីកម្មនៅក្នុងករណីរឿងនេះ។ បើសិនជា គាត់បដិសេធ មិនព្រមធ្វើតាមដោយពុំមានមូលហេតុត្រឹមត្រូវនោះ អង្គជំនុំជម្រះមានសិទ្ធិអំណាច ក្នុងការដាក់ទណ្ឌកម្ម គាត់ពីបទជ្រៀតជ្រែកចូលនៅក្នុងកិច្ចការគ្រប់គ្រងរដ្ឋបាលរបស់តុលាការ[57]។

## III. **អំណះអំណាង**

### *ក-សក្ខីកម្មរបស់ដើមបណ្ដឹងរដ្ឋប្បវេណី ស សារិន គឺមានការជាប់ទាក់ទងគ្នា និងជាភ័ស្តុតាងដែលមានភវនីយភាព ដែលចាំបាច់សម្រាប់អង្គជំនុំជម្រះសាលាដំបូងដើម្បីបញ្ជាក់ពីការពិត*

១៧- ដើម្បីបំពេញភារកិច្ចរបស់អង្គជំនុំជម្រះសាលាដំបូង ក្នុងការពិចារណាលើភ័ស្តុតាងនិងដើម្បី "បញ្ជាក់[]ពីការពិត"[58] អង្គជំនុំជម្រះគួរតែពិនិត្យពិចារណាលើគ្រប់រាល់ភ័ស្តុតាងភវនីយភាពទាំងអស់ ដែលពាក់

---

*ករណីរឿងក្ដីស្ដីពីកិច្ចដំណើរការនីតិវិធីស្ដីពីការប្រមាថមើលងាយតុលាការប្រឆាំងនឹង* Dragan Jokić, សំណុំរឿងលេខ IT-05-88-R77.1, *សាលក្រមលើករណីចោទប្រកាន់ពីបទប្រមាថមើលងាយតុលាការ* (ចុះថ្ងៃទី២៧ មិនា ២០០៩)។ *នៅក្នុងករណីរឿងប្រមាថមើលងាយតុលាការរបស់* Milan Tupajić, សំណុំរឿងលេខ IT-95-5/18-R77.2, *សាលក្រមស្ដីពីករណី ចោទប្រកាន់ពីបទប្រមាថមើលងាយតុលាការ* (ចុះថ្ងៃទី២៤ កុម្ភៈ ២០១២)។

[56] ឯកសារលេខ **E1/185.1** ប្រតិចារិក , ចុះថ្ងៃទី២៩ មេសា ២០១៣។

[57] វិធាន៣៥(១)(ខ) នៃវិធានផ្ទៃក្នុង។ អវតក អាចដាក់ទណ្ឌកម្មចំពោះ " ជនណាណាម្នាក់ ម្នាក់ដែលជ្រៀតជ្រែកដោយចេតនាពិតប្រាកដចូលក្នុងកិច្ចការគ្រប់គ្រងរដ្ឋបាលរបស់អង្គជំនុំជម្រះ រួមទាំងបុគ្គលដែល ... ដោយគ្មានមូលហេតុសមស្របមិនគោរពតាមសេចក្ដីបង្គាប់ឱ្យចូលរួមក្នុងដំណើរការជម្រះក្ដី ឬ មិនផ្ដល់ឯកសារ ឬ ភ័ស្តុតាងផ្សេងទៀតឱ្យសហចៅក្រមស៊ើបអង្កេត ឬ អង្គជំនុំជម្រះ"។

[58] វិធាន៨៧(៤) នៃវិធានផ្ទៃក្នុង។ *សូមអានផងដែរ,* ក្រមនីតិវិធីព្រហ្មទណ្ឌ មាត្រា៣១០ (ឆ្នាំ ២០១៣)។ ក្រមព្រហ្មទណ្ឌរបស់បារាំងផ្ដល់សិទ្ធិអំណាចក្នុងការប្រើប្រាស់ឆន្ទានុសិទ្ធិដ៏ទូលំទូលាយដល់ប្រធានអង្គជំនុំជម្រះ ដែលតាមរយៈនេះប្រធានអង្គជំនុំជម្រះអាច "ចាត់វិធានការណ៍ណាមួយដែលខ្លួនជឿថា មានប្រយោជន៍នៅក្នុងការស្វែងរកការពិត" ។ *ដូចគ្នានឹងខាងលើ* ប្រធានអង្គជំនុំជម្រះមានសិទ្ធអំណាចក្នុងការ " ការកោះហៅជនណាម្នាក់…នៅក្នុងអម្លុងពេលសវនាការ …ដែលខ្លួនយល់ឃើញថាមានប្រយោជន៍សំរាប់ការស្វែងរកការពិត"។ *ដូចគ្នានឹងខាងលើ* នៅពេលដែល "[]សាក្សីដែលបានកោះហៅតាមវិធីនេះ មិនបានធ្វើពិធីសម្បថ ហើយចម្លើយរបស់ពួកគេគ្រាន់តែត្រូវបានចាត់ទុកថា ជាប្រភពពត៏មានតែប៉ុណ្ណោះ" ក្រមព្រហ្មទណ្ឌរបស់បារាំង អាចអនុញ្ញាតឱ្យប្រធានអង្គជំនុំជម្រះកោះហៅដើមបណ្ដឹងរដ្ឋប្បវេណីណាម្នាក់ ធ្វើជា "បុគ្គលម្នាក់" ដែលអាច " មានប្រយោជន៍ដើម្បីស្វែងរកការពិត" ហើយចាត់ទុកសក្ខីកម្មដែលមិនបានធ្វើពិធីសម្បថថាជាប្រភពព័ត៏មានមួយ។ *ដូចគ្នានឹងខាងលើ* ។

ព័ន្ធ[59]។ លើសពីនេះទៅទៀត អង្គជំនុំជម្រះសាលាដំបូងមានភារកិច្ចដើម្បី "ធានាឲ្យប្រាកដថា ការជំនុំជម្រះក្តីមានភាពត្រឹមត្រូវ... ដោយមានការគោរពយ៉ាងពេញលេញដល់សិទ្ធិរបស់ជនជាប់ចោទ និងដល់ការការពារជនរងគ្រោះនិងសាក្សីនានា"[60]។ ការវាយតម្លៃដ៏ត្រឹមត្រូវទៅលើភ័ស្តុតាង គឺរាប់បញ្ចូលទាំងសក្ខីកម្មរបស់ ស សារិន ផងដែរ។

១៨-នៅក្នុងការផ្តល់បទសម្ភាសន៍យ៉ាងលម្អិតរបស់គាត់ជាមួយនឹងមជ្ឈមណ្ឌលឯកសារកម្ពុជា (DC Cam) នៅថ្ងៃទី៥ និងទី៦ ខែឧសភា ឆ្នាំ២០០៩ ស សារិន បានថ្លែងថា គាត់បានមានវត្តមាននៅក្នុងអម្លុងនៃវគ្គអប់រំរៀនសូត្រនៅក្នុងអម្លុងពេល នៃរបបកម្ពុជាប្រជាធិបតេយ្យដែលនៅទីនោះ ទាំង នួន ជា និងទាំង ខៀវ សំផន បានថ្លែងសន្ទរកថា គាំទ្រ ការសម្លាប់ពួកខ្មាំងដែលសន្មត់ថាជាផ្ទៃក្នុង និងពីខាងក្រៅ[61]។ នៅក្នុងការធ្វើសម្ភាសន៍នេះ ស សារិន ក៏បានផ្តល់ភ័ស្តុតាងផងដែរ ទាក់ទងនឹង ក) បទបញ្ជានានារបស់មជ្ឈិមបក្ស បកក ក្នុងការសម្លាប់ ពួកទាហាននៃរបបសាធារណៈរដ្ឋខ្មែរនៅទូទាំងប្រទេស ក៏ដូចជាការអនុវត្តនូវបទបញ្ជានេះ នៅក្នុង ឃុំរបស់គាត់ និង ខ) ការពង្រឹងការអនុវត្តនូវគោលនយោបាយចំពោះខ្មាំងរបស់ បកក តាមរយៈ មន្ទីរសន្តិសុខនានា[62]។

១៩-ដោយសារតែការទទួលខុសត្រូវស្ថិតនៅលើ សហព្រះរាជអាជ្ញា ជាអ្នកត្រូវបង្ហាញភ័ស្តុតាងឲ្យឃើញថា ពិរុទ្ធភាពរបស់ជនជាប់ចោទ ហួសពីវិមតិសង្ស័យនោះ អង្គជំនុំជម្រះគួរតែពិនិត្យពិចារណា លើរាល់ភ័ស្តុតាងទាំងអស់ដែលដាក់នៅចំពោះមុខខ្លួន។ លុះត្រាតែអង្គជំនុំជម្រះរកឃើញថា សំណើសុំ ភ័ស្តុតាង គឺ "គ្មានការជាប់ទាក់ទងគ្នា ឬ មានលក្ខណៈច្រំដែល", មិនអាចរកបាននៅក្នុងអម្លុងពេលសមស្របណាមួយ, មិនសក្តិសមសម្រាប់បង្ហាញអំពីអង្គហេតុដែលខ្លួនបានពោលអះអាងថា នឹងបង្ហាញជូននោះទេ, ច្បាប់មិន អនុញ្ញាតឲ្យ ឬមានចេតនាចង់អូសបន្លាយដល់កិច្ចដំណើរការនីតិវិធី ឬឥតបានការ"[63]។

---

[59] វិធាន៨៧ នៃវិធានផ្ទៃក្នុង។

[60] ច្បាប់ អវតក, មាត្រា៣៣ថ្មី។

[61] ឯកសារលេខ **D230/1.1.874c** ប្រតិចារិកស្តីពីការធ្វើសម្ភាសន៍ ស សារិន ដែលស្រង់ដោយមជ្ឈមណ្ឌលឯកសារកម្ពុជា, ពីថ្ងៃទី៥-៦ ខែឧសភា ឆ្នាំ២០០៩ ត្រង់លេខ ERN 00739547-8, និងលេខ ERN 00739554។

[62] *ដូចគ្នានឹងខាងលើ,* ត្រង់លេខ ERN 00739511, ERN 00739514, និងលេខ ERN 00739555។

[63] វិធាន៨៧ (៣)នៃវិធានផ្ទៃក្នុង។

២០-អង្គជំនុំជម្រះបានផ្តល់ការអនុញ្ញាតាមសំណើរបស់សហព្រះរាជអាជ្ញាដែលសុំឱ្យកោះហៅ ស សារិន ពីព្រោះការទទួលបាននូវភ័ស្តុតាងរបស់គាត់គឺជាការ "ជួយធ្វើឱ្យកិច្ចការគ្រប់គ្រងយុត្តិធម៌បានល្អ"[64]។ នៅក្នុងដំណាក់កាលជំនុំជម្រះក្តីនេះ ភ័ស្តុតាងដែលគាត់មិនទាន់ផ្តល់ គឺនៅតែ "នាំមកនូវការបញ្ជាក់ការពិត" ជាដដែលហើយដែលគួរតែត្រូវបានធ្វើការស្តាប់ចម្លើយដោយអង្គជំនុំជម្រះ។

២១- ដើមបណ្តឹងរដ្ឋប្បវេណី ស សារិន ត្រូវបានអនុញ្ញាតឱ្យចេញពីតុលាការ បន្ទាប់ពីចៅក្រមសហមេធាវីនាំមុខនានា និងសហព្រះរាជអាជ្ញា បានមានឱកាសកាលពីដំបូងក្នុងការសួរដេញដោល រូបគាត់ ប៉ុន្តែនៅមុនពេលមេធាវីការពារក្តី ត្រូវបានផ្តល់ឱកាសឱ្យសួរដេញដោល ដើមបណ្តឹងរដ្ឋប្បវេណី លើភ័ស្តុតាងដែលបានបង្ហាញជូនដែលប្រឆាំងនឹងកូនក្តីរបស់ពួកគេ[65]។ អាស្រ័យហេតុនេះ អង្គជំនុំជម្រះសាលាដំបូងគួរតែកោះហៅសាក្សី ស សារិន សារជាថ្មីម្តងទៀតដើម្បីឱ្យមកផ្តល់សក្ខីកម្មប្រយោជន៍ដើម្បីគោរពខ្ជាប់ខ្ជួនតាមសិទ្ធិរបស់មេធាវីការពារក្តី ក្នុងការទទួលបាននូវការជំនុំជម្រះក្តីដ៏ត្រឹមត្រូវ និងដើម្បីអនុញ្ញាតឱ្យអង្គជំនុំជម្រះ ពិចារណាលើគ្រប់រាល់ភ័ស្តុតាងដែលពាក់ព័ន្ធនិង ភ័ស្តុតាងភរនីយភាពទាំងអស់ នៅក្នុងការស្វែងរកការពិតរបស់ខ្លួន។

២២- បន្ថែមពីលើនេះ សហព្រះរាជអាជ្ញា បានដាក់ជូននូវកំណត់ហេតុស្តាប់ចម្លើយសាក្សី កាលពីលើកមុនរបស់ ស សារិន ដើម្បីជាភ័ស្តុតាងក្នុងករណីនេះ[66]។ ពីព្រោះគាត់បានផ្តល់ចម្លើយដោយផ្ទាល់ទាក់ទងអំពីអំពើនិងការប្រព្រឹត្តរបស់ជនជាប់ចោទ កំណត់ហេតុស្តាប់ចម្លើយសាក្សីទាំងនេះត្រូវបានកោសលប់ចេញមួយចំនួន។ ភ័ស្តុតាង និងភ័ស្តុតាងភរនីយភាពមួយចំនួន ដែលជាប់ទាក់ទងខ្លាំងជាងគេបំផុតនៅក្នុងកំណត់ហេតុស្តាប់ចម្លើយសាក្សីទាំងនេះ ចាំបាច់ត្រូវតែមាននៅក្នុងផ្នែកនានាដែលត្រូវបានគេកោសលប់ចេញខ្លះនោះ។ បើសិនជាអង្គជំនុំជម្រះបដិសេធមិនព្រមធ្វើការកោះហៅ ស សារិន សារជាថ្មីម្តងទៀតឱ្យមកផ្តល់សក្ខីកម្មនោះ គឺអង្គជំនុំជម្រះអាចនឹងត្រូវបានទប់ស្កាត់មិនឱ្យមានលទ្ធភាព ដើម្បីពិចារណាលើភ័ស្តុតាងជាគន្លឹះ នៅក្នុងការកំណត់សម្រេចអំពីការពិតនៅក្នុងករណីរឿងនេះហើយ។

---

[64] វិធាន៨៧*ស្ទួន* (២)នៃវិធានផ្ទៃក្នុង។ ចូរកត់សម្គាល់ថា វិធាន២៤ ហាមមិនឱ្យអង្គជំនុំជម្រះកោះហៅមកធ្វើជាសាក្សី "ជនណាដែលម្នាក់ដែលមានភ័ស្តុតាងថាមានការទទួលខុសត្រូវខាងព្រហ្មទណ្ឌ," ក៏ប៉ុន្តែ មានករណីលើកលែងមួយចំនួន ដូចដែលមានចែងនៅក្នុងវិធាន២៨។ វិធាន២៤(៤)។

[65] ឯកសារលេខ **E1/185.1** ប្រតិចារិក, ចុះថ្ងៃទី២៩ មេសា ២០១៣។

[66] ឯកសារលេខ **D230/1.1.874c** ប្រតិចារិកស្តីពីការធ្វើសម្ភាសន៍ ស សារិន ដែលស្រង់ដោយមជ្ឈមណ្ឌលឯកសារកម្ពុជា, ពីថ្ងៃទី៥-៦ ខែឧសភា ឆ្នាំ២០០៩។

## ខ-ឋានៈជាភាគីដើមបណ្ដឹងរដ្ឋប្បវេណីរបស់ ស សារិន គួរតែ ត្រូវបានពិនិត្យពិចារណាឡើងវិញ

២៣- លើសពីនេះ និងជាជម្រើសផ្សេងទៀត សហព្រះរាជអាជ្ញាសូមជូនជាមតិដើម្បី ពិចារណា ថាអង្គជំនុំជម្រះ គួរតែពិចារណាឡើងវិញ លើឋានៈជាភាគីដើមបណ្ដឹងរដ្ឋប្បវេណីរបស់ ស សារិន ជាពិសេស បើសិនជាគាត់បដិសេធ មិនព្រមផ្ដល់សក្ខីកម្មជាថ្មីម្ដងទៀត។ ស សារិន ត្រូវបានទទួលលក្ខណៈសម្បត្តិជាភាគីដើមបណ្ដឹងរដ្ឋប្បវេណី នៅក្នុងករណីរឿងនេះដោយផ្អែកលើមូលដ្ឋាននៃពាក្យសុំរបស់គាត់អនុលោមតាមវិធាន២៣*ស្ទួន* នៃវិធានផ្ទៃក្នុង[67]។ បើសិនជាសាលក្រមសម្រេចថាមានទោសត្រូវបានចេញនោះ ឋានៈជាដើមបណ្ដឹងរដ្ឋប្បវេណីធ្វើឲ្យ ស សារិន មានសិទ្ធិអាចទទួលបាននូវសំណងជួសជុល[68]។ ប៉ុន្តែ ស សារិន នៅតែបដិសេធមិនផ្ដល់ភ័ស្តុតាងដែលសហព្រះរាជអាជ្ញានិងអង្គជំនុំជម្រះបានកំណត់ដើម្បីនាំមកនូវការបញ្ជាក់ពីការពិត។ ការបដិសេធមិនផ្ដល់ភ័ស្តុតាងទៅតាមដីកាបង្គាប់ដែលមានសុពលរបស់អង្គជំនុំជម្រះនេះ គឺជាការដកយកមកវិញនូវការទាមទាររបស់ដើមបណ្ដឹងរដ្ឋប្បវេណី[69]។

២៤- អង្គជំនុំជម្រះមានភារកិច្ចក្នុងការ "រក្សាការពារជានិច្ចនូវផលប្រយោជន៍នានា"[70] របស់ជនរងគ្រោះ និង "រក្សាតុល្យភាពរវាង សិទ្ធិរបស់ភាគីនានា"[71]។ តាមរយៈការបដិសេធរបស់គាត់ ស សារិន កំពុងតែធ្វើឲ្យខូចដល់ផលប្រយោជន៍ផ្សេងៗរបស់ភាគីដើមបណ្ដឹងរដ្ឋប្បវេណីដទៃទៀត ដែលគោលជំហររបស់ពួកគេ គួរតែអង្គជំនុំជម្រះគិតគូរយកចិត្តទុកដាក់នៅពេលពិនិត្យពិចារណាក្នុងការប្រើឆន្ទានុសិទ្ធិរបស់ខ្លួនចំពោះបញ្ហានេះ។ បើសិនជា ស សារិន មិនមែនជាភាគីដើមបណ្ដឹងរដ្ឋប្បវេណី នៅក្នុងករណីនេះ តទៅទៀតទេនោះ គាត់ត្រូវឈប់លែងមានផលប្រយោជន៍ជាដើមបណ្ដឹងរដ្ឋប្បវេណីទៀតហើយៗ ក្លាយទៅជាសាក្សីធម្មតាវិញ ដែលត្រូវតែផ្ដល់សក្ខីកម្មដោយមានការធ្វើសម្បថ។

---

[67] ឯកសារលេខ **D404/2/4** សេចក្ដីសម្រេចលើបណ្ដឹងសាទុក្ខប្រឆាំងនឹងដីកាសម្រេចរបស់សហចៅក្រមស៊ើបអង្កេតស្ដីពីភាពអាចទទួលយកបាននៃពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណី, ចុះថ្ងៃទី២៤ មិថុនា ២០១១។

[68] វិធាន២៣*ស្ទួនបួន* នៃវិធានផ្ទៃក្នុង។

[69] វិធាន២៣*ស្ទួន* (៥) នៃវិធានផ្ទៃក្នុង "នៅគ្រប់ពេលទាំងអស់ នៅក្នុងដំណាក់កាលជំនុំជម្រះនិងតមកទៀត ដើមបណ្ដឹងរដ្ឋប្បវេណី អាចដកខ្លួនចេញពីក្រុមនៃដើមបណ្ដឹងរដ្ឋប្បវេណី"។

[70] វិធាន២១(១) នៃវិធានផ្ទៃក្នុង។

[71] វិធាន២១(១) (ក) នៃវិធានផ្ទៃក្នុង។

## IV ដំណោះស្រាយដែលស្នើ

២៥- អាស្រ័យដោយមូលហេតុដូចបានគូសបញ្ជាក់ខាងលើនេះ សហព្រះរាជអាជ្ញា សូមស្នើដោយគោរពដល់អង្គជំនុំជម្រះមេត្តាពិចារណាឡើងវិញ លើសេចក្ដីសម្រេចស្ដីពីការបដិសេធលើសំណើដែលសុំឲ្យកោះហៅដើមបណ្ដឹងរដ្ឋបវេណី ស សារិនជាថ្មីម្ដងទៀត ហើយ ៖

១-កោះហៅ ស សារិន ដើម្បីមកផ្ដល់សក្ខីកម្ម ហើយបន្ថែមពីលើនេះ ជូនដំណឹងដល់គាត់ថា៖

ក-សំណើសុំផ្ដល់វិធានការការពាររបស់គាត់ត្រូវបានធ្វើការវាយតម្លៃរួចហើយ និងបានរកឃើញថាមិនមានការចង្អុលបង្ហាញភ័ស្ដុតាងទេ។

ខ- គាត់មានភារកិច្ចផ្ដល់ភ័ស្ដុតាង

គ-ការបដិសេធមិនផ្ដល់សក្ខីកម្មអាចនាំទៅដល់ការដាក់ទណ្ឌកម្ម ស្របតាមវិធាន៣៥ និង

២-ប្រសិនបើ លោក ស សារិន នៅតែបន្តបដិសេធក្នុងការផ្ដល់សក្ខីកម្ម៖

ក-ពិចារណាឡើងវិញក្នុងឋានៈរបស់គាត់ជាដើមបណ្ដឹងរដ្ឋប្បវេណី និង

ខ-ដាក់ទណ្ឌកម្មប្រឆាំងនឹងរូបគាត់ អនុលោមតាមវិធាន៣៥

| កាលបរិច្ឆេទ | ឈ្មោះ | ទីកន្លែង | ហត្ថលេខា |
|---|---|---|---|
| ថ្ងៃទី១៨ ខែកក្កដា ឆ្នាំ២០១៣ | **លោកស្រី ជា លាង** សហព្រះរាជអាជ្ញា | ភ្នំពេញ | [signature] |
| | **លោក** William SMITH សហព្រះរាជអាជ្ញារង | | [signature] |